# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

*******

យើងខ្ញុំទាំងអស់គ្នា គឺជាក្រុមយុវជន បណ្តាញ សមាគម និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការលើកិច្ចការពារបរិស្ថាននៅកម្ពុជា។

## សូមគោរពជូន
## ឯកឧត្តម Kevin Choek ឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋសឹង្ហបុរី ប្រចាំប្រទេសកម្ពុជា

**កម្មវត្ថុ** : សំណើសុំចូលជួបពិភាក្សាជាមួយ **ឯកឧត្តម** ស្តីពីគោលជំហររបស់សាធារណៈរដ្ឋសឹង្ហបុរីក្នុងការទិញខ្សាច់ពីប្រទេសកម្ពុជា។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន ឯកឧត្តម មេត្តាជ្រាបថា ដោយសារតែការបូមខ្សាច់របស់កម្ពុជា សម្រាប់នាំចេញទៅប្រទេសសឹង្ហបុរីកន្លងមក និងបច្ចុប្បន្នបានធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ជីវៈចំរុះ និងការប្រកបមុខរបរនេសាទរបស់សហគមន៍មូលដ្ឋាន។ អាស្រ័យហេតុនេះ ទើបយើងខ្ញុំ ស្នើសុំចូលចួបជាមួយឯកឧត្តម ដើម្បីពិភាក្សា ដំណើរការ និងគោលជំហររបស់រដ្ឋាភិបាលនៃសាធារណៈសឹង្ហបុរី ទាក់ទងទៅនឹងការទិញខ្សាច់ពីប្រទេសកម្ពុជា។

**ឯកឧត្តមជាទីគោរព!**

**សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែន** បានផ្ញើរលិខិតមួយ កាលពីថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០១៥ ដែលជាការឆ្លើយតប ទៅនឹងការស្នើរសុំការបកស្រាយពីសំណាក់តំណាងរាស្ត្ររដ្ឋសភាមួយរូប។ ក្នុងលិខិតរបស់ **សម្តេចនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ខ្សាច់ដែលកំពុងតែធ្វើការចាប់យក ក្នុងខេត្តកោះកុង គឺសម្រាប់តែនាំចេញទៅលក់នៅក្រៅប្រទេសតែមួយមុខប៉ុណ្ណោះ។

កាលពី ខែសីហា ឆ្នាំ២០១៥ កន្លងទៅ អត្ថបទមួយដែលចុះផ្សាយនៅក្នុងកាសែតខេមបូឌាដេលី បានធ្វើការដកស្រង់សម្តីរបស់ កាពីទែន របស់កប៉ាល់បូមខ្សាច់ឈ្មោះ **Inkar jerahar** បានបញ្ជាក់ថា "ខ្សាច់នៅក្នុងកប៉ាល់របស់គាត់ មានគោលដៅនាំចេញទៅប្រទេសសឹង្ហបុរី"។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ការទិញខ្សាច់របស់ប្រទេសសឹង្ហបុរីនៅប្រទេសកម្ពុជា នៅតែបន្តនាពេលបច្ចុប្បន្ននេះ គឺវាដូចទៅនិងអ្វីដែលតាមអង្គការឃ្លាំ

មើលពិភពលោក បានសរសេរក្នុងរបាយការណ៍នាឆ្នាំ២០១០កន្លងមកថា ប្រទេសសឹង្ហបុរី ពិតជាបានទិញខ្សាច់នៅក្នុងប្រទេសកម្ពុជាប្រាកដមែន។

**ឯកឧត្តមជាទីគោរព!**

ចំណុចដែលសំខាន់មួយទៀត សហគមន៍នេសាទមូលដ្ឋាន មានក្តីព្រួយបារម្ភយ៉ាងខ្លាំង ចំពោះផលប៉ះពាល់ ដែលបណ្តាលមកពីសកម្មភាព ចាប់យកខ្សាច់នៅក្នុងព្រែក ស្ថិតក្នុងខេត្តកោះកុង ដែលបង្ករឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ដោយសារជីវចម្រុះនៅក្រោមទឹក មានការធ្លាក់ចុះ និងផ្តល់ផលប៉ះពាល់ដល់បរិស្ថានផងដែរ។

ខាងក្រោមនេះ ជាសំនួរមួយចំនួន ដែលយើងស្នើរសុំឱ្យ **ឯកឧត្តម** មេត្តា ជួយបញ្ជាក់ នៅពេលដែលយើងមានការជួបជាមួយគ្នា៖

១. តើប្រទេសសឹង្ហបុរី នៅតែបន្តទិញខ្សាច់ពីប្រទេសកម្ពុជាដដែលឬក៏យ៉ាងណា? ប្រសិនជាបានទិញពិតប្រាកដមែន គិតចាប់ពីឆ្នាំ២០០៨មក តើប្រទេសសឹង្ហបុរីបានទិញខ្សាច់ពីប្រទេសកម្ពុជាចំនួនប៉ុន្មានតោនផងដែរ?

២. តើក្រសួងណាខ្លះ ក្នុងរដ្ឋាភិបាលសឹង្ហបុរី ដែលទទួលខុសត្រូវក្នុងការ ទិញខ្សាច់នៅក្នុងប្រទេសកម្ពុជា? ហើយខ្សាច់ទាំងអស់នេះត្រូវបានយកទៅប្រើប្រាស់សំរាប់ធ្វើអ្វីខ្លះ?

៣. តើក្រុមហ៊ុនខ្សាច់ឯកជន ឈ្មោះអ្វីខ្លះ ដែលបានលក់ខ្សាច់ជូនដល់រដ្ឋាភិបាលសឹង្ហបុរីកន្លងមក?

៤. តើមាននីតិវិធីអ្វីខ្លះ សំរាប់ការទិញយកខ្សាច់របស់ប្រទេសកម្ពុជា ពីសំណាក់រដ្ឋាភិបាលសឹង្ហបុរី?

៥. តើរដ្ឋាភិបាលសឹង្ហបុរី បាននឹងកំពុងគោរពច្បាប់ និងសន្ធិសញ្ញាដែលពាក់ពន្ធ័ ទៅនឹងការនាំចូលខ្សាច់ រួមនិងផលប៉ះពាល់ដែលបណ្តាលមកពី ការធ្វើអាជីវកម្មខ្សាច់ដែរឬទេ?

អាស្រ័យដូចបានជម្រាបជូន ខាងលើ សូមឯកឧត្តមមេត្តា ចាត់ចែង និងរៀបចំឱ្យមានជំនួបនេះដោយសេចក្តីអនុគ្រោះ។ ចំពោះពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំ ឯកឧត្តមអាចសម្រេចទៅតាមការគួរ។

សូម **ឯកឧត្តម** មេត្តាទទួលយកនូវការគោរពដ៏ស្មោះអំពីយើងខ្ញុំទាំងអស់គ្នា។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

ហត្ថលេខា និងឈ្មោះ